**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩[illegible] ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍



www.pheakdeylaw.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើត គណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ ដែលសរសេរជាអក្សរកាត់ថា **គ.អ.ទ.** ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ប្រធាន

២- ឯកឧត្តម **ទី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម **ស៊ូ តិរិទ្ធ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៤- ឯកឧត្តម **និត ចន្ថា** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធានអចិន្ត្រៃយ៍

៥- ឯកឧត្តម **លឹម ស៊ីដេនីន** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៦- ឯកឧត្តម **យុទ្ធ ភូថង** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៧- ឯកឧត្តម **តែ គុយស៊ាង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៨- ឯកឧត្តម **ហ៊ី ធីរៈ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

៩- ឯកឧត្តម **សោរី ជំនះ** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១០- ឯកឧត្តម **គឹម សុភ័ណ** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

១១- ឯកឧត្តម **ជា ឧុត្ធី** អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

១២- លោកជំទាវ **ចាន់ សុម៉ាលី** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួងបរិស្ថាន សមាជិក

១៣- ឯកឧត្តម **ឆាយ ឬទ្ធីសែន** អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១៤- លោកជំទាវ **នៅ សុខម៉ារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

១៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក

១៦- ប្រធានគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍន៍ទេសចរណ៍រាជធានីខេត្តទាំង២៥ សមាជិក

១៧- លោក **សុខ សុគុណា** ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ក្រសួងទេសចរណ៍ សមាជិកអចិន្ត្រៃយ៍និងជាលេខាធិការ

**គ.អ.ទ.** អាចមានសមាសភាពបន្ថែមមកពីក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនិងដៃគូពាក់ព័ន្ធ តាមការចាំបាច់។/.



www.pheakdeylaw.com

**ប្រការ២ .-**

គ.អ.ឆ. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយចីរភាព
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ ពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍២០១២-២០២០ ប្រកបដោយប្រសិទ្ធភាព
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ទេសចរណ៍ ការអនុវត្តច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ ព្រមទាំងផ្នែកដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍
- រៀបចំរបាយការណ៍ បូកសរុបការងារអនុវត្ត ស្ថានភាពទេសចរណ៍ លើកយោបល់ ឬដំណោះស្រាយ ព្រមទាំងវិធានការនានាជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេច
- ពិនិត្យ អនុម័ត និងគ្រប់គ្រងគម្រោងផែនការសកម្មភាពរបស់ **គ.អ.ឆ.**។

**ប្រការ៣ .-**

ប្រធាន **គ.អ.ឆ.** ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់រៀងរាល់ដំណាច់ឆមាសនីមួយៗ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធាន ១(មួយ)រូប ដែលបានទទួលសិទ្ធិពីប្រធានដឹកនាំការប្រជុំរបស់ **គ.អ.ឆ.**។

ប្រធាន **គ.អ.ឆ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬ ផ្នែកឯកជនចូលរួមប្រជុំពិគ្រោះ ពិភាក្សាយោបល់ និងសិក្សាស្រាវជ្រាវលើរាល់ការងារទាំងឡាយដែលទាក់ទងនឹង **គ.អ.ឆ.**។

**ប្រការ៤ .-**

**គ.អ.ឆ.** មានលេខាធិការដ្ឋានមួយជាជំនួយការ នៅទីស្តីការក្រសួងទេសចរណ៍។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.អ.ឆ.**។

**ប្រការ៥ .-**

**គ.អ.ឆ.** មានសិទ្ធិប្រើប្រាស់និមិត្តសញ្ញានិងត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៦ .-**

ការចំណាយសម្រាប់កិច្ចដំណើរការ **គ.អ.ឆ.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងកញ្ចប់ថវិការបស់ក្រសួងទេសចរណ៍។



www.pheakdeylaw.com

គ.អ.ឧ. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាននិងមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់កិច្ចដំណើរការការងាររបស់ខ្លួន។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com